# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ :...០៧៧០ ៥៧...... ប.ស្ក

## សូមគោរពជូន
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ៖** របាយការណ៍ស្តីពីលទ្ធផលវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុ

**យោង៖** លិខិតលេខ ១៦១៨ សជណ.កស ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយស សូមគោរពរាយការណ៍ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង ជាប្រធានកិត្តិយសនៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ(គ.ជ.គ.ប.អ.) មេត្តាជ្រាបថា ក្នុងនាមជាប្រធាន គ.ជ.គ.ប.អ. ក្រសួងបរិស្ថានបានរៀបចំវេទិកាជាតិលើកទី៣ ស្តីពីការប្រែប្រួលអាកាសធាតុក្រោមប្រធានបទ "*ធ្វើសកម្មភាពឆ្ពោះទៅការអភិវឌ្ឍដោយចីរភាពក្នុងបរិបទប្រែប្រួលអាកាសធាតុ*" ចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៣។ វេទិកាជាតិនេះ មានគោលបំណងផ្តល់ឱកាសសម្រាប់ពិភាក្សា ចែករំលែកព័ត៌មានពាក់ព័ន្ធនឹងប្រធានបទប្រែប្រួលអាកាសធាតុ សំដៅពង្រឹងវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសផ្តោតលើការផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា និងលទ្ធផលដែលសម្រេចបាន សំដៅជានានូវកិច្ចសហប្រតិបត្តិការ និងភាពបន្សុីគ្នារវាងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលជាមួយបណ្តាគំនិតផ្តួចផ្តើមប្រែប្រួលអាកាសធាតុនានា។

ពិធីបើកអង្គវេទិកាជាតិលើកទី៣ នេះ បានប្រារព្ធនៅព្រឹកថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** និងមានការចូលរួមពីសំណាក់សមាជិកព្រឹទ្ធសភា រដ្ឋសភា សមាជិករាជរដ្ឋាភិបាល មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ គ្រឹះស្ថានឧត្តមសិក្សា ស្ថានទូត ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការជាតិ-អន្តរជាតិ និស្សិត និងសហភាពសម្ព័ន្ធយុវជនកម្ពុជា សរុបប្រមាណ ៨៥០នាក់។ វគ្គបច្ចេកទេសនៃអង្គវេទិកា បានចាប់ផ្តើមនៅរសៀលថ្ងៃទី៥ រហូតដល់ ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៣ នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញភូគីត្រា ដោយមានសមាជិក សមាជិកាចូលរួមសរុបប្រមាណ ៤០០នាក់។ វគ្គបច្ចេកទេសនេះ ផ្តោតលើប្រធានបទសំខាន់ៗដូចជា៖

១)ព័ត៌មានវិទ្យាសាស្ត្រអំពីការប្រែប្រួលអាកាសធាតុ វឌ្ឍនភាពនៃការអនុវត្ត និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា

២)ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យ

៣)ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ

៤)កិច្ចសហប្រតិបត្តិការអន្តរជាតិ និង

៥)គោលជំហររបស់ប្រទេសកម្ពុជា សម្រាប់សន្និសីទកំពូលលើកទី១៩ នៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។



អគារលេខ៤៨ មហាវិថីសម្តេចព្រះសីហនុ ទន្លេបាសាក់ ចំការមន ភ្នំពេញ ទូរស័ព្ទ: ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារ: ០២៣ ២១២ ៥៤០

វេទិកាជាតិលើកទី៣ នេះទទួលបាននូវលទ្ធផល និងអនុសាសន៍សំខាន់ៗដូចខាងក្រោម៖

- ប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣
- លើកកម្ពស់ការកៀរគរធនធាន ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ការផ្ទេរបច្ចេកវិទ្យា ការកសាងសមត្ថភាព និងការបង្កើនការយល់ដឹងជាសាធារណៈ
- ស្នើឱ្យក្រសួងអប់រំ យុវជន និងកីឡា ពិនិត្យពិចារណាដាក់បញ្ចូលមុខវិជ្ជាការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីអប់រំ និងបណ្តុះបណ្តាលនានា រួមទាំងកម្មវិធីសិក្សាក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ
- ឈានចេញពីគំរូនៃការអនុវត្តគម្រោងដាច់ដោយឡែកពីគ្នា ទៅរកអភិក្រមកម្មវិធី ការប្រមូលផ្តុំមូលនិធិ និងការគាំទ្រថវិកា
- ជំរុញឱ្យមានការកសាងសមត្ថភាពបច្ចេកទេសតាមក្រសួង-ស្ថាប័នបន្ថែម ដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ
- ជំរុញឱ្យក្រសួង-ស្ថាប័នទាំងអស់ ត្រូវធ្វើសមាហរណកម្មផែនការប្រែប្រួលអាកាសធាតុតាមវិស័យរបស់ខ្លួនចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- លើកទឹកចិត្តឱ្យស្ថាប័នពាក់ព័ន្ធចូលរួមបង្កើតផែនការសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដោយឈរលើមូលដ្ឋានផែនការយុទ្ធសាស្ត្រដែលមានស្រាប់
- ពង្រឹងយន្តការសម្របសម្រួលការងារប្រែប្រួលអាកាសធាតុ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកា
- លើកកម្ពស់ការចូលរួមពីវិស័យឯកជនក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ តាមរយៈការបង្កើតបរិយាកាសងាយស្រួលសម្រាប់អ្នកវិនិយោគនៅកម្ពុជា
- អំពាវនាវឱ្យដៃគូអភិវឌ្ឍន៍ផ្តល់មូលនិធិបន្ថែមដល់សកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា
- ឯកភាពលើសេចក្តីព្រាងគោលជំហររបស់រាជរដ្ឋាភិបាលសម្រាប់យកទៅចរចានៅក្នុងសន្និសីទលើកទី១៩ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ នៅទីក្រុងវ៉ាសូវី ប្រទេសប៉ូឡូញ ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងជាប្រធានកិត្តិយសនៃគ.ជ.គ.ប.អ. មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត ពីខ្ញុំបាទ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ [illegible] ឆ្នាំ២០១៣

**រដ្ឋមន្ត្រី**

**និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ**

**សាយ សំអាល់**

<u>ចម្លងជូន៖</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ខុទ្ទកាល័យឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី
- គ្រប់សមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
- ឯកសារ កាលប្បវត្តិ